# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមីនា ឆ្នាំ២០១៤

នៅក្នុងខែមីនា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅៈ

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បានៈ

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន ០១លើក

-ទទួលសំណើផ្សេងៗពីរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងគណបក្សរាជានិយមសរុបចំនួន ១២១សំណើ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្រចំនួន ១២០សំណើរ និងលិខិតផ្សេងៗចំនួន ០២លិខិត ។

១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ ព្រឹទ្ធសភា បានៈ

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន ០១លើក

-អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវិវត្តកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ" នៅសាលសិក្ខាសាលាបណ្ណាល័យ

-អញ្ជើញជាតំណាងរបស់សម្តេចអគ្គមហាធម្មពោធិសាលប្រធានព្រឹទ្ធសភា ក្នុងពិធីទទួលព្រះរាជដំណើរ ព្រះករុណា ព្រះមហាក្សត្រ និងសម្តេចព្រះវររាជមាតាជាតិខ្មែរ យាងត្រឡប់ពីពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចុះការងារមូលដ្ឋានចំនួន ០៤លើក នៅរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ,



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ខេត្តព្រៃវែង និងខេត្តកំពង់ចាម

-បានទទួលសំណេះសំណាល និងផ្តល់មតិណែនាំដល់គណៈប្រតិភូគណៈកម្មការទី៥ និងគណៈកម្មការទី៨ នៃព្រឹទ្ធសភា មុនចេញដំណើរទៅបំពេញទស្សនកិច្ច នៅក្រៅប្រទេស ចំនួន ០២លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៨១ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន៖**

-អនុញ្ញាតឲ្យគណៈប្រតិភូនារីដឹកនាំដោយលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចូលជួបសម្តែងការគួរសម ក្នុងឱកាសអបអរសាទរខួបលើកទី១០៣ ទិវាសិទ្ធនារីអន្តរជាតិ

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើកវេទិកាស្តីពី "ព្រឹទ្ធសភា និងការពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋាន និងសមភាពយេនឌ័រ " នៅវត្តទន្ទេអុំ ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើកកិច្ចប្រជុំពិភាក្សាស្តីពី "ច្បាប់សវនកម្ម និងស្តង់ដាសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា" នៅសណ្ឋាគារ៉ាហ្វល ឡឺរ៉ូយ៉ាល់

-អញ្ជើញអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសការងារជូនមន្ត្រីរាជការព្រឹទ្ធសភា

-អញ្ជើញចុះជួបសំណេះសំណាលជាមួយប្រធាន អនុប្រធានការិយាល័យអប់រំស្រុកក្រុង ទាំង១១ ក្នុងខេត្តកណ្តាល នៅសាលាខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨៧ច្បាប់ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែមីនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម ៖

**៣.១ មុខងារនីតិកម្ម**

-ប្រជុំពិនិត្យ និងឆ្លងឯកសារស្តីពី "សេចក្តីកំណត់ និងនីតិវិធីអនុវត្តន៍ចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣"

**៣.២ មុខងារត្រួតពិនិត្យ**

បានជួបសវនាការជាមួយឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្វែងយល់អំពីការទាក់ទងនឹងសិទ្ធិមនុស្សនៅគ្រប់ភូមិសិក្សា ។

### ៣.៣ មុខងារតំណាង

-ទទួលពាក្យបណ្តឹងចំនួន ០៣ករណី

-ប្រជុំពិភាក្សាស្តីពី "ច្បាប់សវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ"

-ប្រជុំពិនិត្យ និងពិភាក្សាលើគម្រោងទស្សនកិច្ចស្វែងរកព័ត៌មានស្តីពី "ការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ"

-ជួបសំណេះសំណាលជាមួយប្រធានអង្គការលូជ័រអំពី "ការអំពាវនាវរកជំនួយមនុស្សធម៌មកជួយប្រជាពលរដ្ឋកម្ពុជា"

-ជួបសំណេះសំណាលជាមួយលោកបណ្ឌិត **អ៊ឹម វិបុល** សមាជិកក្រុមប្រឹក្សាភាសាខ្មែរនៃរាជបណ្ឌិតសភា និងជាសមាជិកក្រុមមេធាវីកម្ពុជាស្តីពី សិទ្ធិ និងការអប់រំ

-បានអនុញ្ញាតឲ្យអ្នកវិនិយោគមកពីប្រទេសកូរ៉េ , អូស្ត្រាលី ,បារាំង, ក្រុមហ៊ុន Halla Group និងជប៉ុន ចូលជួបសំណេះសំណាល និងពិភាក្សាការងារ ដោយផ្តោតសំខាន់ទៅលើវិស័យកសិកម្ម

-បទបង្ហាញស្តីពី នីតិវិធីនៃការទទួលពាក្យបណ្តឹង

-វេទិកាស្តីពី "រាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជនលើកទី១៧ និងបញ្ហាប្រឈមនានា"

-វេទិកាស្តីពី "ព្រឹទ្ធសភា និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងសមភាពយេនឌ័រ"

-វេទិកាថ្នាក់ស្រុកស្តីពី "សេវាសាធារណៈរបស់ឃុំ" ក្នុងស្រុកស៊ីធរកណ្តាល និងស្រុកពាមរំង ខេត្តព្រៃវែង

-សិក្ខាសាលាស្តីពី "ការវិវត្តនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ"

-សិក្ខាសាលាស្តីពី "ការចូលរួមរបស់ស្ត្រី ដើម្បីលើកម្ពស់តម្លៃសីលធម៌សង្គម" ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ០៨មីនា លើកទី១០៣ ឆ្នាំ២០១៨

-សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៨ ក្នុងប្រធានបទ " ប្រទេសកម្ពុជា ក្នុងប្រាំឆ្នាំទៅមុខ" ដើម្បីកំណែទម្រង់ និងភាពប្រកួតប្រជែងនៅក្នុងតំបន់ ក្រោយធ្វើសមាហរណកម្ម

-បទសម្ភាសនៅស្ថានីយ៍ទូរទស្សន៍ CNC ពីគោលនយោបាយគ្រឿងស្រវឹងនៅកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ៩០លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា ស្វែងយល់ និងតាមដានការអនុវត្តច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាព សិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យព្រម ទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន ១៦៥លើក ។

**៣.៤ មុខងារព័ត៌មាន**

-សមាជិកគណៈកម្មការទី២, គណៈកម្មការទី៤ និងគណៈកម្មការទី៧ បានអញ្ជើញចុះបេសកកម្មស្វែងរកព័ត៌មានអំពី "ការអនុវត្ត និង ត្រួតពិនិត្យថវិកាថ្នាក់ ក្រោមជាតិក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ" នៅខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ។

-សមាជិកគណៈកម្មការទី៣ បានអញ្ជើញ ចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ និងសម្រង់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកែប ខេត្តកំពត និង ខេត្តព្រះសីហនុ

-សមាជិកគណៈកម្មការទី៥ ព្រឹទ្ធសភា បានចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងផ្សព្វផ្សាយព័ត៌មាន នៅខេត្តតាកែវ, ខេត្តកោះកុង, ខេត្តព្រះសីហនុ និងខេត្តកំពត ។

-សមាជិកគណៈកម្មការទី៧ បានអញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពី ការអនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធជាមួយវិស័យអប់រំ ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍ នៅខេត្តកំពង់ធំ និងសៀមរាប ។

**៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញទៅចូលរួមក្នុងមហាសន្និបាតលើកទី១៣០ របស់សហភាពអន្តរសភា (IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និងធ្វើទស្សនកិច្ចផ្លាស់ប្ដូរបទពិសោធន៍ការងារ នៅខេត្តចំប៉ាសាក់ ខេត្តសេកុង និងខេត្តអ័ត្តាពឺ នៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ

-ឯកឧត្តម **ប៊ូ ថង** និងឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** រួមជាមួយក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ឡាវ បានធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ នៅខេត្តចំប៉ាសាក់ ខេត្តសេកុង និងខេត្តអត្តាពឺរ នៅសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ ។

-ឯកឧត្តម **ឈិត គឹមយាត** បានអញ្ជើញទៅទស្សនកិច្ចផ្លូវការជាមិត្តភាព នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ។

-ឯកឧត្តម **អ៊ុក គង់**, ឯកឧត្តម **ម៉ែន ស៊ីផាន់** និងឯកឧត្តម **ហុង ទូហាយ** បានអញ្ជើញចូលរួមពិធី "បុណ្យទិវានិយាយភាសាបារាំងលើកទី៨" នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-សមាជិកគណៈកម្មការទី៩ ដឹកនាំដោយលោកជំទាវ **ទី បូរ៉ាស៊ី** បានអញ្ជើញបំពេញបេសកកម្មដើម្បីសិក្សាស្វែងយល់ និងដកបទពិសោធន៍ការងារ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-សមាជិកគណៈកម្មការទី៨ ដឹកនាំដោយលោកជំទាវ **មាន សំអាន** បានអញ្ជើញបំពេញបេសកកម្មដើម្បីសិក្សាស្វែងយល់ និងដកបទពិសោធន៍ការងារ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ

ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

លេខ ០៣៥ / ០៤៧៤ /អ.ពស/

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតអម

## សូមគោរពជូន

**សម្តេច** ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧទារ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**ឯកឧត្តម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

**ឯកឧត្តម** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ឯកឧត្តម** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ឯកឧត្តម** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ឯកឧត្តម** រដ្ឋមន្ត្រីក្រសួងព័ត៌មាន

| ល.រ | បរិយាយ | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០១៤ ។ | ០១ | ដើម្បីគោរពជូនជ្រាបជាព័ត៌មាន ។ |

ភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**អ៊ុំ-សារិទ្ធ**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh